# សាលាបង្រៀនគួររ៉ដវែល

## កិច្ចសន្យារវាងសាលានិងសិស្ស

## P.A.S.S PROGRAM

ក្នុងនាមខ្ញុំបាទឈ្មោះ **កូវ ពុទ្ធារ័ត្ន រ៉ដវែល** ជានាយកគ្រប់គ្រងសាលាបង្រៀនគួររ៉ដវែល ហៅថា**ភាគី ក** សូមធ្វើកិច្ចសន្យា ចំពោះមុខសិស្សឈ្មោះ ______________________________ ដែលមានថ្ងៃខែឆ្នាំកំណើត ____________________ ស្នាក់នៅអាសយដ្ឋាន ________________________________________________________________ ហៅថា**ភាគី ខ**។ ភាគី ក នឹងសន្យាថា សាលាយើងនឹងខំឲ្យអស់ពីសមត្ថភាពក្នុងការបណ្តុះបណ្តាលសិស្សឈ្មោះខាងលើឲ្យរីកចម្រើនទាំងការគិត ទាំងការធ្វើ និងចំណេះដឹងដែលមាន យកទៅប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ 2020 ហើយនឹងទទួលបានលទ្ធិផលទាបបំផុតគឺ E (ជាប់)។ សាលាបង្រៀនគួររ៉ដវែលនឹងសន្យាគ្រប់លក្ខខណ្ឌខាងក្រោម៖

- គ្រប់គ្រូបង្រៀននឹងខំបង្រៀនប្អូនឲ្យអស់ពីកម្លាំងកាយចិត្តដើម្បីទទួលបានលទ្ធិផលល្អបំផុត
- ផ្តល់នូវថ្នាក់បំប៉នខាងកុំព្យូទ័រ ខាងសុខភាព ខាងនិយាយជាសាធារណៈ ខាងកីឡា ខាងគំនូរ និងសិល្បៈ
- ផ្តល់នូវថ្នាក់រៀនក្លិបនិងវគ្គសិក្សាជំនួយថ្ងៃសៅរ៍នឹងថ្ងៃអាទិត្យសម្រាប់ធ្វើលំហាត់និងកិច្ចពិភាក្សាបន្ថែម
- ផ្តល់នូវអ្នកជំនួយការនិងទីប្រឹក្សាម្នាក់ដែលតែងតែយកចិត្តទុកដាក់និងតាមជួយប្អូនជានិច្ច
- ផ្តល់បរិស្ថានដែលប្អូនអាចលូត អាចរៀនចេះ និង អាចធ្វើអ្វីដែលខ្លួនចូលចិត្ត
- ផ្តល់ទីកន្លែងសិក្សាដែលមានសុវត្ថិភាពដើម្បីឲ្យប្អូនអាចធ្វើខ្លួនឲ្យមានជាសុខភាព
- រៀបចំសកម្មភាពថ្មីៗ ប្លែកៗ ដូចជាដំណើរកម្សាន្ត កិច្ចការងារសង្គម និង ជប់លៀងជាដើមសម្រាប់សិស្ស

ក្នុងនាមប្អូនជាភាគី ខ ជាសិស្សឈ្មោះខាងលើ ប្អូនក៏មានកាតព្វកិច្ចនិងតួនាទីជាសិស្សដែលប្អូនត្រូវតែបំពេញដើម្បីឲ្យកិច្ចសហការណ៍រវាងសាលាហើយនឹងប្អូនអាចមានភាពរលូនទៅរកភាពជោគជ័យសម្រាប់ជីវិតសិក្សារបស់ប្អូន។ កាតព្វកិច្ចនិងតួនាទីរបស់ប្អូនជាសិស្សរ៉ដវែលរួមមាន៖

- ប្អូនត្រូវតែមករៀនឲ្យទាន់ពេល និងទៀងទាត់ជារៀងរាល់ថ្ងៃ បើប្អូនអវត្តមានច្រើនជាង ៥ ដងក្នុងមួយខែ សាលាមានសិទ្ធិលុបឈ្មោះប្អូនចេញពីកម្មវិធី PASS នេះ។
- រាល់កិច្ចការដែលគ្រូដាក់ឲ្យ ប្អូនត្រូវតែព្យាយាមធ្វើឲ្យអស់ពីសមត្ថភាព ទោះបីជាមិនត្រូវទាំងអស់ក៏ដោយ ក៏ប្អូនត្រូវតែព្យាយាមទាំងអស់ដែរ។ បើគ្រូមើលទៅឃើញថា ប្អូនមិនបានខំ ឬ ខ្ជិលច្រអូសក្នុងការធ្វើកិច្ចការដែលគាត់ដាក់ឲ្យ សាលាមានសិទ្ធិដកឈ្មោះប្អូនចេញពីកម្មវិធី PASS នេះ។
- ប្អូនត្រូវចូលរួមរាល់សកម្មភាពរបស់សាលា រួមមានការងារសង្គម ដំណើរកម្សាន្តឬកម្មសិក្សា ពិធីជប់លៀងផ្សេងៗទៀត ដើម្បីធ្វើជាស្ពានសម្រាប់ភ្ជាប់មិត្តភាពរបស់សិស្សនិងសិស្ស ហើយគ្រូនិងសិស្ស។
- ប្អូនត្រូវមករៀនថ្នាក់បំប៉នថ្ងៃសៅរ៍នឹងថ្ងៃអាទិត្យបន្ថែម នេះមិនមានជាជម្រើសទេ ជាតម្រូវការ។
- គណនៈគ្រប់គ្រងសាលា ឬគ្រូបង្រៀនអាចថែមលក្ខខណ្ឌផ្សេងៗទៀតទៅតាមតម្រូវការរបស់ថ្នាក់នីមួយៗ។

ភាគីទាំងពីរបានអាននិងយល់ស្របតាមគ្រប់លក្ខខណ្ឌខាងលើ។ បើមានករណីដែលភាគី ខ ធ្វើតាមគ្រប់លក្ខខណ្ឌខាងលើរួចហើយ តែនៅតែប្រឡងមិនជាប់ ភាគី ក នឹងសន្យាថាប្រគល់លុយសងវិញ 100% នៃលុយដែលបានបង់រួច។ តែបើសិនជាភាគី ខ មិនបានបំពេញលក្ខខណ្ឌណាមួយ ភាគី ក នឹងបញ្ឈប់ឈ្មោះសិស្សចេញពីកម្មវិធី PASS នេះ ឬ មានករណីណាមួយដែលមិនទាក់ទងនឹងសាលាដែលធ្វើឲ្យភាគី ខ ប្រឡងធ្លាក់ ភាគី ក នឹងមិនសងលុយវិញជាដាច់ខាត។

ស្នាមមេដៃនាយកគ្រប់គ្រង                                        ស្នាមមេដៃសិស្ស

No. 57 Street 318, Phnom Penh, Cambodia
www.rodwell.center | Tel: 076/088/096-763-9355